# សន្តិភាពស៊ីវិល ?

សន្តិភាពស៊ីវិល វាលែងត្រឹមតែជា ពាក្យ ឬ លទ្ធវត្ថុ ទៀតឡើយ, វាជាមរតកដ៏មានតម្លៃដែលត្រូវតែថែរក្សានៅក្នុងប្រទេសមួយ ធ្លាប់ស្គាល់វិនាដកម្ម ប្រកបដោយការឈឺចាប់។ តែការថែរក្សានេះ ត្រូវចាំបាច់ពឹងផ្អែក លើកម្លាំងរបស់ប្រទេសជាតិ : ប្រជាពលរដ្ឋ, រដ្ឋ, គោលការណ៍ជាតិ និង វប្បធម៌ជាតិ។ ទី១ ត្រូវចាំបាច់មាន នយោបាយផ្សះផ្សាជាតិ ក្នុងស្មារតីយុត្តៈ ដើម្បីលុបដាន នៃជម្លោះក្នុងអតីតកាល, ទី២ ត្រូវមាននីតិរដ្ឋ ដើម្បីធានាយុត្តិធម៌សង្គម, ទី៣ គោលការណ៍ជាតិ គឺ រក្សាតុល្យភាពអចិន្ត្រៃ រវាងតម្រូវការ នៃជីវិតសង្គម និង សេរីភាពរបស់បុគ្គល, អនុវត្ត លទ្ធិប្រជាធិបតេយ្យសេរីឥតខ្ចោះ និង មានគោលការណ៍នយោបាយ នៃកិច្ចការបរទេស ឈរលើការថែរក្សាសន្តិភាពជាមួយប្រទេសជិតខាង ដោយការពារផលប្រយោជន៍ជាតិ និង ត្រូវតែមាន តុល្យភាពក្នុងទំនាក់ទំនងអន្តរជាតិ, ទីបញ្ចប់ ត្រូវតែការពារ វប្បធម៌ជាតិ ជាអាទិភាព តាមរយៈការបើកឱ្យមានភាពចម្រុះដ៏ល្អ ដើម្បីធ្វើឱ្យជីវិតវាកាន់តែរស់រវើកនៅលើកពិភពលោក ដ៏ស្អុគស្មាញ។ បំណើកនេះ វាជាចម្លើយប្រឆាំងនឹងសារធាតុពុល នៃការបន្សុត នៃវប្បធម៌ និង ជាតិនិយមជ្រុល។ កត្តាទាំង៤ នេះ គឺជាចំនួនអប្បបរមា ដើម្បីជីវិតរបស់ជាតិ។ គ្រប់មហិច្ឆតាហួសកំរិត និង មិនសមាមាត្រនឹងកម្លាំងជាតិ វាគ្រាន់តែជាការបំភាន់, តែបើគ្មានសោះ យុទ្ធសាស្ត្រវាយលុកការពារប្រយោជន៍ជាតិ គឺប្រជាជាតិនឹងស្លាប់ដែរ៕